## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

លេខ៖ ៤២៣១ កបទ.សអ.អគ្គ-ដ្ឋាន

### សូមជម្រាបជូន
### ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត លោក លោកស្រី អគ្គកុងស៊ុល និង កុងស៊ុលកិត្តិយស នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅបរទេស

**កម្មវត្ថុ៖** អំពីការចូលរួមទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ចូលមកកម្ពុជា ។

**យោង៖** អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ សម្តេចតេជោនាយករដ្ឋមន្ត្រី ។

ខ្ញុំសូមជម្រាប ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត លោក លោកស្រី អគ្គកុងស៊ុល និង កុងស៊ុលកិត្តិយស ថា យោងតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក្រសួងសូមណែនាំនូវវិធានការមួយចំនួនបន្ថែមលើវិធានការរបស់ក្រសួងសុខាភិបាល ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ចូលមកកម្ពុជា ដូចខាងក្រោម៖

១. បង្កើនការអប់រំ និងណែនាំដល់បងប្អូនពលរដ្ឋខ្មែរដែលកំពុងស្នាក់នៅបរទេស អំពីហានិភ័យខ្ពស់នៃការចម្លងវីរ៉ុសកូវីដ-១៩បំប្លែងថ្មី (Delta / Delta Plus) និងអំពាវនាវកុំឱ្យមានការបន្លាស់ទីពីទីកន្លែងមួយទៅទីកន្លែងមួយប្រសិនបើពុំមានការចាំបាច់ និងជៀសវាងការធ្វើដំណើរវិលត្រឡប់មកកម្ពុជាវិញក្នុងអំឡុងពេលនេះ ព្រោះអាចបង្កហានិភ័យនៃការឆ្លងក្នុងពេលធ្វើដំណើរ និងអាចនាំយកជំងឺកូវីដ-១៩ ចូលមកកម្ពុជាថែមទៀត។

២. ដោយឡែក ចំពោះស្ថានទូតកម្ពុជានៅទីក្រុងបាងកក និងស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តសាកែវ ត្រូវណែនាំដល់បងប្អូនពលករខ្មែរដែលកំពុងធ្វើការនៅប្រទេសថៃ ទាំងស្របច្បាប់ និងមិនស្របច្បាប់ កុំឱ្យមានការព្រួយបារម្ភ ព្រោះភាគីថៃនឹងសហការជាមួយភាគីកម្ពុជា ដើម្បីផ្តល់ភាពស្របច្បាប់ជូនដល់ពលករខ្មែរដែលកំពុងធ្វើការនៅប្រទេសថៃ។

៣. យុទ្ធសាស្ត្រគន្លឹះចំនួន ៦ ដាក់ចេញដោយ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដូចមានជូនភ្ជាប់ ។

សូម ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត លោក លោកស្រី អគ្គកុងស៊ុល និងកុងស៊ុលកិត្តិយស អនុវត្តតាមការណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ និងទទួលនូវការរាប់អានពីខ្ញុំ ។

ថ្ងៃពុធ ១៣រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២១

**ជ.រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការប្រចាំការ**

**អ៊ុច បូរិទ្ធ**

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល : mfaic@mfaic.gov.kh

តាមរយៈកិច្ចប្រជុំគណៈកម្មការជាតិប្រយុទ្ធប្រឆាំងនឹងជំងឺ កូវីដ-១៩ តាមប្រព័ន្ធវីដេអូ កាលពីព្រឹកថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនូវយុទ្ធសាស្ត្រ គន្លឹះចំនួន ៦ ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ដូចខាងក្រោម ៖

I. **យុទ្ធសាស្ត្រទី១ ៖ បន្តទប់ស្កាត់ការនាំចូលមេរោគកូវីដ-១៩ បំប្លែងថ្មី** តាមរយៈវិធានការដូចខាងក្រោម៖

1. ពង្រឹងការធ្វើដំណើរចូលមកកម្ពុជា តាមច្រកព្រំដែនផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស ជាពិសេសព្រំដែនកម្ពុជា-ថៃ និងកម្ពុជា-វៀតណាម។
2. បង្កើនការធ្វើតេស្តរហ័ស (Rapid Test)តាមច្រកព្រំដែន និងបណ្តាខេត្តនានា។
3. ពង្រឹងធ្វើចត្តាឡីស័កឱ្យបានត្រឹមត្រូវ ជាពិសេសនៅបណ្តាខេត្តជាប់ព្រំដែន។

II. **យុទ្ធសាស្ត្រទី២ ៖ បំព្រួញតំបន់ដែលឆ្លង និងកាត់បន្ថយចំនួនឆ្លងថ្មី** តាមរយៈវិធានការ ដូចខាងក្រោម ៖

1. វិធានការការអប់រំ
2. វិធានការសុខាភិបាល
3. វិធានការរដ្ឋបាល និងច្បាប់

III. **យុទ្ធសាស្ត្រទី៣៖ ខិតខំព្យាបាលអ្នកជំងឺឱ្យជាសះស្បើយ និងកាត់បន្ថយចំនួនអ្នកស្លាប់** តាមរយៈវិធានការដូចខាងក្រោម ៖

1. ស្វះស្វែងរកប្រភពថ្នាំដែលមានប្រសិទ្ធភាពក្នុងការព្យាបាល និងរៀបចំផែនការបញ្ជាទិញបន្ថែម ហើយការព្យាបាលគ្រប់ទីកន្លែងទាំងអស់ ត្រូវមានស្តង់ដារតែមួយ ។
2. រៀបចំមន្ទីរពេទ្យព្យាបាលបន្ថែមនៅថ្នាក់ស្រុក និងបំពាក់សម្ភារៈសង្គ្រោះបន្ទាន់(ICU) ឱ្យបានគ្រប់គ្រប់គ្រាន់។
3. ហ្វឹកហ្វឺនគ្រូពេទ្យបន្ថែម ។
4. រៀបចំផែនការបញ្ជាទិញសម្ភារៈសុខាភិបាលចាំបាច់ផ្សេងៗឱ្យបានឆាប់រហ័ស និងអនុវត្តការដាក់ព្យាបាលនៅតាមផ្ទះ។

IV. **យុទ្ធសាស្ត្រទី៤ ៖ ការរុករក និងគ្រប់គ្រង** តាមរយៈវិធានការ ដូចខាងក្រោម ៖

1. រៀបចំទីកន្លែងយកសំណាក និងការយកសំណាកទៅពិនិត្យ
2. ពង្រឹងសមត្ថភាពមន្ទីរពិសោធ និងការរុករកមេរោគបំប្លែងថ្មី
3. ពង្រីកការធ្វើតេស្តរហ័សឱ្យបានទូលំទូលាយ
4. រឹតបន្តឹងការធ្វើចត្តាឡីស័កឱ្យបានត្រឹមត្រូវ និងម៉ត់ចត់
5. តាមដានដោយបច្ចេកវិទ្យាព័ត៌មាន

V. **យុទ្ធសាស្ត្រទី៥ ៖ ការរៀបចំការបូជា និងការបញ្ចុះសពឱ្យបានល្អ** តាមរយៈវិធានការ ដូចខាងក្រោម ៖

1. រៀបចំឈាបនដ្ឋានសម្រាប់បូជាសពនៅទីកន្លែងដែលមិនទាន់មាន (គ្រប់ខេត្តទាំងអស់ត្រូវពិនិត្យមើលភូមិសាស្ត្រជាក់ស្តែង)
2. ប្រើប្រាស់ឈាបនដ្ឋានរបស់វត្តដែលនៅជិត តែត្រូវធានាសុវត្ថិភាព ដោយសហការជាមួយព្រះចៅអធិការវត្ត និងគណៈកម្មការវត្ត

3. រៀបចំផលិតក្តារមឈូស សម្រាប់ដាក់សពយកទៅបូជា ឬកប់
4. រៀបចំដីសម្រាប់កប់សពទៅតាមប្រពៃណីរបស់ជនជាតិភាគតិច និងខ្មែរ-ឥស្លាម

## VI. យុទ្ធសាស្ត្រទី៦ ៖ ការបញ្ជាទិញ និងការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩

1. ប្រកាសដាក់ចេញយុទ្ធសាស្ត្រទិញវ៉ាក់សាំងការពារជំងឺកូវីដ-១៩ ឱ្យបានយ៉ាងហោចណាស់ចាក់ជូនប្រជាពលរដ្ឋឱ្យបាន១០លាននាក់ នៅជំហានដំបូង និងសម្រាប់ក្មេងអាយុក្រោម ១៨ឆ្នាំនៅជំហានបន្ទាប់ទៀត។
2. ផ្តោតលើមិត្តចិនជាបង្អែកយុទ្ធសាស្ត្រសម្រាប់ការផ្គត់ផ្គង់វ៉ាក់សាំង ចំណែកប្រភពផ្សេងទៀតជាប្រភពគាំទ្រ។